ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៣៧០ ព.ណ....ឃល

# សេចក្តីជូនដំណឹង
## ស្តីពីការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការឱ្យចូលបម្រើការងារ
## ក្នុងក្របខ័ណ្ឌក្រសួងពាណិជ្ជកម្ម ឆ្នាំ ២០១៤

ក្រសួងពាណិជ្ជកម្មសូមជម្រាបជូនដំណឹងដល់សិស្ស និស្សិត និងសាធារណៈជនទាំងពីរភេទឱ្យបានជ្រាបថា៖ ក្រសួងពាណិជ្ជកម្ម នឹងធ្វើការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការចូលបម្រើការងារ ក្នុងក្របខ័ណ្ឌក្រសួងសម្រាប់ ឆ្នាំ២០១៤ ចំនួន ៦០ កន្លែង ដើម្បីបំពេញការងារនៅតាមមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត និងនៅទីស្តីការក្រសួង ដូចខាងក្រោម៖

**ក. សម្រាប់បម្រើការងារនៅតាមមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ចំនួន ៣០ កន្លែង ៖**

| ល.រ | អង្គភាព | ចំនួនក្របខ័ណ្ឌ | | ល.រ | អង្គភាព | ចំនួនក្របខ័ណ្ឌ | |
|---|---|---|---|---|---|---|---|
| | | ក | ខ | | | ក | ខ |
| ១ | មន្ទីរព.ណ ខេត្តកណ្តាល | ១ | ១ | ១៤ | មន្ទីរព.ណ ខេត្តប៉ៃលិន | ១ | |
| ២ | មន្ទីរព.ណ រាជធានី | ១ | ១ | ១៥ | មន្ទីរព.ណ ខេត្តកោះកុង | ១ | |
| ៣ | មន្ទីរព.ណ ខេត្តសៀមរាប | ១ | | ១៦ | មន្ទីរព.ណ ខេត្តស្ទឹងត្រែង | ១ | ១ |
| ៤ | មន្ទីរព.ណ ខេត្តកំពង់ស្ពឺ | ១ | | ១៧ | មន្ទីរព.ណ ខេត្តព្រះវិហារ | ១ | |
| ៥ | មន្ទីរព.ណ ខេត្តបាត់ដំបង | ១ | ១ | ១៨ | មន្ទីរព.ណ ខេត្តតាកែវ | ១ | |
| ៦ | មន្ទីរព.ណ ខេត្តពោធិសាត់ | ១ | | ១៩ | មន្ទីរព.ណ ខេត្តព្រៃវែង | ១ | |
| ៧ | មន្ទីរព.ណ ខេត្តព្រះសីហនុ | ១ | | ២០ | មន្ទីរព.ណ ខេត្តស្វាយរៀង | ១ | |
| ៨ | មន្ទីរព.ណ ខេត្តកំពត | ១ | | ២១ | មន្ទីរព.ណ ខេត្តកំពង់ចាម | ១ | |
| ៩ | មន្ទីរព.ណ ខេត្តកំពង់ធំ | ១ | | ២២ | មន្ទីរព.ណ ខេត្តក្រចេះ | | ១ |
| ១០ | មន្ទីរព.ណ ខេត្តកំពង់ឆ្នាំង | ១ | | ២៣ | មន្ទីរព.ណ ខេត្តរតនគិរី | ១ | |
| ១១ | មន្ទីរព.ណ ខេត្តបន្ទាយមានជ័យ | ១ | | ២៤ | មន្ទីរព.ណ ខេត្តមណ្ឌលគិរី | ១ | |
| ១២ | មន្ទីរព.ណ ខេត្តកែប | ១ | | ២៥ | មន្ទីរព.ណ ខេត្តត្បូងឃ្មុំ | ១ | ១ |
| ១៣ | មន្ទីរព.ណ ខេត្តឧត្តរមានជ័យ | ១ | | | | | |
| *សរុបសម្រាប់ថ្នាក់រាជធានី-ខេត្ត ចំនួន ៣០ កន្លែង (ក្របខ័ណ្ឌ «**ក**» ចំនួន ២៤ កន្លែង និង «**ខ**» ចំនួន ០៦ កន្លែង)* | | | | | | | |

**ខ. សម្រាប់បម្រើការងារនៅទីស្តីការក្រសួង ចំនួន ៣០ កន្លែង រួមមាន ៖**

- ជំនាញខាងព័ត៌មានវិទ្យា កម្រិតបរិញ្ញាបត្រឡើងទៅចំនួន ០៨ កន្លែង
- ជំនាញខាងសេដ្ឋកិច្ច ពាណិជ្ជកម្ម គ្រប់គ្រង សវនកម្ម គណនេយ្យ ហិរញ្ញវត្ថុ ភាសាអង់គ្លេស រដ្ឋបាលទូទៅ និងមុខជំនាញប្រហាក់ប្រហែល ចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅ ចំនួន ១៧ កន្លែង
- ជំនាញខាងច្បាប់ ០២ កន្លែង
- ជំនាញខាងគីមីសាស្ត្រ និងម្ហូបអាហារ ចំនួន ០៣ កន្លែង

**គ. លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស ៖**

១. បេក្ខជនទាំងពីរភេទ ត្រូវមានសញ្ជាតិខ្មែរ

២. បេក្ខជនដែលមានបំណងដាក់ពាក្យសុំចុះឈ្មោះប្រឡងចូលក្របខ័ណ្ឌ «**ក**» គឺជាបេក្ខជនដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើងទៅ ឬសញ្ញាបត្រមានតម្លៃសមមូល និងត្រូវមានអាយុមិនលើសពី **៣០**ឆ្នាំ គិតមកដល់ថ្ងៃប្រឡង។

៣. ចំពោះបេក្ខជនដែលមានបំណងដាក់ពាក្យសុំចុះឈ្មោះប្រឡងចូលក្របខ័ណ្ឌ« **ខ** »គឺជា បេក្ខជនដែលមានសញ្ញាបត្រចាប់ពីមធ្យមសិក្សាឯកទេសឡើងទៅ (បរិញ្ញាបត្ររង) ឬសញ្ញាបត្រមានតម្លៃសមមូល និងត្រូវមានអាយុមិនលើសពី ២៥ឆ្នាំ គិតមកដល់ថ្ងៃប្រឡង។

៤. បេក្ខជនទាំងអស់ ត្រូវមានចំណេះដឹងជាបឋមលើជំនាញកុំព្យូទ័រ ( Microsoft Word & Excel ) ដែលមានវិញ្ញាបនបត្របញ្ជាក់ការសិក្សាត្រឹមត្រូវ។

៥. បេក្ខជនមានសញ្ញាបត្របាក់ឌុបខាងភាសាចិន បន្ថែមលើចំណេះដឹងភាសាអង់គ្លេស ត្រូវបានផ្តល់ពិន្ទុអាទិភាព ចំនួន ០២ កន្លែង។

៦. **បេក្ខជនជាជនពិការ** ដែលមានសមត្ថភាពសមស្របអាចបម្រើការងារបាន ត្រូវបានផ្តល់អាទិភាពពិសេសក្នុងការជ្រើសរើសយ៉ាងតិចបំផុត២កន្លែង ក្នុងចំណោមចំនួនបេក្ខជនសរុប។

៧. **បេក្ខជនជាស្ត្រីភេទ** នឹងត្រូវបានលើកទឹកចិត្ត។

**ឃ. កាលបរិច្ឆេទទទួលពាក្យ និងទីកន្លែងទទួលពាក្យសុំប្រឡង ៖**

- ការទទួលពាក្យសុំចុះឈ្មោះប្រឡង នឹងប្រព្រឹត្តទៅនៅរៀងរាល់ម៉ោងធ្វើការ ចាប់ផ្តើមពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី ៣០ **ខែឧសភា ឆ្នាំ២០១៤** ត្រឹមវេលាម៉ោង ១៧: ០០នាទី ជាកាលបរិច្ឆេទចុងក្រោយ។
- បេក្ខជនត្រូវសរសេរ និងបំពេញសំណុំលិខិតសុំចុះឈ្មោះប្រឡង ត្រូវមកដាក់ពាក្យសុំចុះឈ្មោះប្រឡងប្រជែងដោយខ្លួនឯងនៅតាមទីកន្លែងកំណត់ ៖
  - ១. បេក្ខជនដែលដាក់ពាក្យសុំចុះឈ្មោះប្រឡងប្រជែង ចូលបម្រើការងារនៅតាមមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត អាចដាក់ពាក្យនៅតាមមន្ទីរពាណិជ្ជកម្មបាន ឬអាចមកដាក់នៅលេខាធិការដ្ឋាន នៃគណៈកម្មការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការរបស់ក្រសួង (នាយកដ្ឋានបុគ្គលិក)។
  - ២. បេក្ខជនដែលដាក់ពាក្យសុំចុះឈ្មោះប្រឡងប្រជែង ចូលបម្រើការងារនៅទីស្តីការក្រសួង ត្រូវមកដាក់ពាក្យនៅលេខាធិការដ្ឋាន នៃគណៈកម្មការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការរបស់ក្រសួង (នាយកដ្ឋានបុគ្គលិក)។

**ង. សំណុំលិខិតសុំចុះឈ្មោះប្រឡង ៖**

| | | |
|---|---|---|
| ១. ពាក្យសុំចុះឈ្មោះប្រឡងមានបិទតែមប្រ៊ីយ៍ (មានគំរូស្រាប់) | ចំនួន | ០១ ច្បាប់ |
| ២. ច្បាប់ចម្លងសញ្ញាបត្រទុតិយភូមិ (បាក់ឌុប) និងសញ្ញាបត្រជំនាញ ដោយមានការបញ្ជាក់ទទួលស្គាល់ជាផ្លូវការ | ចំនួន | ០១ ច្បាប់ |
| ៣. ជីវប្រវត្តិសង្ខេបមានបិទរូបថត (4x6 ) | ចំនួន | ០១ ច្បាប់ |
| ៤. សលាកបត្រឯកត្តជន (មានគំរូស្រាប់) | ចំនួន | ០២ ច្បាប់ |
| ៥. រូបថតថ្មី (4x6 ដោយថតចំពីមុខ) | ចំនួន | ០២ សន្លឹក |
| ៦. បង្កាន់ដៃទទួលពាក្យ (មានគំរូស្រាប់) | ចំនួន | ០២ ច្បាប់ |
| ៧. កិច្ចសន្យា (មានគំរូស្រាប់) | ចំនួន | ០១ ច្បាប់ |
| ៨. ច្បាប់ចម្លងប័ណ្ណគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅ | ចំនួន | ០១ ច្បាប់ |
| ៩. លិខិតថ្កោលទោស (ក្រោយពេលប្រឡងជាប់) | ចំនួន | ០១ ច្បាប់ |

**ច. វិញ្ញាសាប្រឡង ៖**

- *សម្រាប់ការប្រឡងចូលប្រភេទក្របខ័ណ្ឌ « **ខ** » ៖*

| | | |
|---|---|---|
| ១. វិញ្ញាសាវប្បធម៌ទូទៅ | *មេគុណ ១* | *រយៈពេល ២ ម៉ោង* |
| ២. វិញ្ញាសាភាសាអង់គ្លេស | *មេគុណ ១* | *រយៈពេល ១ ម៉ោង និង ៣០ នាទី* |

- *សម្រាប់ការប្រឡងចូលប្រភេទក្របខ័ណ្ឌ « **ក** » ៖*

| | | |
|---|---|---|
| ១. វិញ្ញាសាវប្បធម៌ទូទៅ | *មេគុណ ១* | *រយៈពេល ២ ម៉ោង* |
| ២. វិញ្ញាសាភាសាអង់គ្លេស | *មេគុណ ១* | *រយៈពេល ១ ម៉ោង និង ៣០ នាទី* |
| ៣. វិញ្ញាសាព័ត៌មានវិទ្យា | *មេគុណ ១* | *រយៈពេល ២ ម៉ោង* |

៤. វិញ្ញាសាសេដ្ឋកិច្ចពាណិជ្ជកម្ម ឬវិញ្ញាសាដែលទាក់ទងនឹងមុខជំនាញ ដែលបេក្ខជនស្នើសុំចុះឈ្មោះប្រឡងដូចបាន
បញ្ជាក់ខាងលើ *មេគុណ ១* *រយៈពេល ២ ម៉ោង*

៥. វិញ្ញាសាច្បាប់ *មេគុណ ១* *រយៈពេល ២ ម៉ោង*

៦. វិញ្ញាសាគីមីសាស្ត្រ និងម្ហូបអាហារ *មេគុណ ១* *រយៈពេល ២ ម៉ោង*

**ឆ. កាលបរិច្ឆេទ និងមណ្ឌលប្រឡង ៖**

១. កាលបរិច្ឆេទប្រឡង - **ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ ២០១៤**

<u>*ពេលព្រឹក*</u> ម៉ោង ០៧: ៣០នាទី ដល់ម៉ោង ១១: ៣០នាទី

<u>*ពេលរសៀល*</u> ម៉ោង ១៤: ៣០នាទី ដល់ម៉ោង ១៦: ៣០នាទី

២. មណ្ឌលប្រឡង - នឹងជូនដំណឹងនៅពេលប្រកាសបិទឈ្មោះបេក្ខជន នៅទីស្តីការក្រសួងពាណិជ្ជកម្ម (ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ)។

ក្នុងករណីចាំបាច់ពាក់ព័ន្ធនឹងចំនួនបេក្ខជនប្រឡង ដែលនាំឱ្យមានការផ្លាស់ប្តូរមណ្ឌលប្រឡង ឬថ្ងៃប្រឡង គណៈកម្មការនឹងធ្វើសេចក្តីជូនដំណឹងជាសាធារណៈ នៅមុនថ្ងៃប្រឡងចំនួន ៧ ថ្ងៃ។

ព័ត៌មានលម្អិតផ្សេងៗទៀត បេក្ខជនអាចមកទំនាក់ទំនងដោយផ្ទាល់នៅលេខាធិការដ្ឋាននៃគណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ របស់ក្រសួងពាណិជ្ជកម្ម នៅទីស្តីការក្រសួង (នាយកដ្ឋានបុគ្គលិក) និងនៅតាមមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត រៀងរាល់ម៉ោងធ្វើការ ឬអាចពិនិត្យមើលនៅក្នុងគេហទំព័រក្រសួងពាណិជ្ជកម្ម តាមអាសយដ្ឋាន <u>www.moc.gov.kh</u>

*រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៤*

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការប្រឡងប្រជែង**

**ជ្រើសរើសមន្ត្រីរាជការចូលបម្រើការងារក្នុងក្របខ័ណ្ឌឆ្នាំ២០១៤**

**តឹកវ៉េត កំរង**

**<u>ចម្លងជូន៖</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ
- គ្រប់អគ្គនាយកដ្ឋាន អង្គភាព មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត
- ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន
- ឯកសារ-កាលប្បវត្តិ